អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹង ដីកាបង្គាប់ឲ្យដកព័ត៌មានចេញរបស់សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០៣

យោងតាមវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក *សេចក្តីពិចារណារបស់* អង្គបុរេជំនុំជម្រះ *ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសំណុំរឿង ០០៣* ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ និង *ដីកាសម្រេចលើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣* (“ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ”) ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ លោក អាន់ឌ្រូ ឃេលី សូមដកសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់គាត់វិញ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ។

សេចក្តីថ្លែងការណ៍ជាសាធារណៈនេះ បានចេញក្រោយពេលសហចៅក្រមស៊ើបអង្កេតបានដាក់ *សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣* របស់ខ្លួន ដែលក្នុងនោះមាន (១) សេចក្តីសង្ខេបអំពីឧក្រិដ្ឋកម្មដែលតម្រូវឲ្យស៊ើបអង្កេតក្នុងសំណុំរឿង ០០៣; (២) ទស្សនៈអំពីឧក្រិដ្ឋកម្មទាំងនោះដែលមិនត្រូវបានគេស៊ើបអង្កេតឲ្យបានពេញលេញ; (៣) គម្រោងរួមអំពីប្រភេទនៃកិច្ចស៊ើបសួរបន្ថែមដែលសហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងស្នើសុំ; (៤) សេចក្តីជូនដំណឹងមួយដល់សាក្សីសក្តានុពលអំពីរយៈពេលកំណត់១៥ថ្ងៃ សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ និង (៥) ចេតនារបស់សហព្រះរាជអាជ្ញា ដើម្បីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតពន្យាររយៈពេលកំណត់នេះ ។

ដីកាបង្គាប់ឲ្យដកព័ត៌មានចេញ បានសម្រេចថា សហព្រះរាជអាជ្ញាអន្តរជាតិត្រូវដកចេញនូវសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់ខ្លួនចេញ ដោយសារហេតុផលពីរយ៉ាងគឺគាត់៖ (១) ពុំមានសិទ្ធិ “ធ្វើការបង្ហាញមតិយោបល់ជាសាធារណៈទាក់ទងនឹង “ឧក្រិដ្ឋកម្មដែលតម្រូវឲ្យមានការស៊ើបសួរ” នោះឡើយ”, និង (២) បាន “រំលោភលើវិធាននៃការរក្សាការសម្ងាត់” ដោយការផ្តល់ព័ត៌មានដល់សាធារណជនអំពីសំណើនានាដែលគាត់មានបំណងស្នើសុំ ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

ខណៈដែលចៅក្រមនៃអង្គបុរេជំនុំជម្រះ បានរកឃើញជាឯកច្ឆ័ន្ទថា សហចៅក្រមស៊ើបអង្កេត មានសិទ្ធិចេញដីកាបង្គាប់ឲ្យដកព័ត៌មានចេញ នោះពួកគាត់មិនមានលទ្ធភាពអាចឈានដល់នូវសេចក្ដីសម្រេចមួយបញ្ជាក់ពីអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ បានឡើយ ។

ស្ដីពីបញ្ហាពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០៣ នៅក្នុង *សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេច ស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលោក រ៉ូប៊ឺត ហាមីល* ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានរកឃើញនូវរបកគំហើញមួយចំនួន រួមមាន៖

(១) សហចៅក្រមស៊ើបអង្កេតមិនបានផ្ដល់នូវព័ត៌មានណាមួយ អំពីកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០៣ ដើម្បីឲ្យជនរងគ្រោះនានា អាចមានលទ្ធភាពក្នុងការធ្វើជាដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានឡើយ ដែលជាការផ្ទុយពីការអនុវត្តន៍នៅក្នុងសំណុំរឿងលេខ ០០៣ ។

(២) គ្មានអ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ត្រូវបាន “ស្ថិតនៅក្នុងស្ថានភាពដើម្បីនឹងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិក្នុងការចូលរួមនៅក្នុងកិច្ចស៊ើបសួរឡើយ” ហើយនេះ “ហាក់ដូចជាបណ្ដាល” មួយផ្នែកធំ មកពីការខ្វះព័ត៌មានជុំវិញការស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣នេះ ។

(៣) ហេតុនេះជាលទ្ធផលគឺ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងលេខ០០៣ ដែល “មានការធ្វើមិនដឹងមិនឮចំពោះសិទ្ធិរបស់ជនរងគ្រោះនោះ រហូតមកទល់ពេលនេះ ធ្វើឲ្យមានការខូចខាតដល់សិទ្ធិទាំងនេះ” ហើយ “ការបដិសេធដែលមិនឲ្យ [ជនរងគ្រោះនានា] អាចមានលទ្ធភាពចូលរួមនៅក្នុងកិច្ចស៊ើបសួរបាននេះ អាចជាការដកហូតពីសហចៅក្រមស៊ើបអង្កេតនូវព័ត៌មានដ៏មានសារៈសំខាន់ក្នុងការស្វែងរកការពិតរបស់ខ្លួន ដែលបណ្ដាលឲ្យកិច្ចស៊ើបសួរមិនបានពេញលេញ ហើយដែលនាំឲ្យលេចឡើងនូវការមន្ទិលសង្ស័យអំពីភាពលំអៀងរបស់សហចៅក្រមស៊ើបអង្កេត” ។

(៤) “ព័ត៌មានតែមួយគត់ដែលមានស្រាប់សំរាប់ទុកឲ្យសាធារណៈជនអាចរកមើលបាន ទាក់ទងអំពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ ត្រូវបានផ្ដល់ជូននៅក្នុងសេចក្ដីប្រកាសព័ត៌មានមួយដែលបានចេញដោយ សហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យដកព័ត៌មានចេញ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតខាងលើនេះ” ៕

---